# ២—សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៦

**សេចក្តីសំរេចលេខ ១៦ សសរ**

**ស្តីពីការបង្កើតគណៈកម្មការសំរាប់រុករក និងជួយ**

**សង្គ្រោះយន្តហោះ និងនាវាពេលមានឧប្បត្តិហេតុ**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

– បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណា ចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– តាមសំណើរបស់ឯកឧត្តមអនុរដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

**សំរេច**

**ប្រការ ១** : ត្រូវបានបង្កើតគណៈកម្មការមួយសំរាប់រុករក និងសង្គ្រោះយន្តហោះ និងនាវាពេលមានឧប្បត្តិហេតុ ដែលមានសមាសភាពដូចតទៅៈ ÷

១_ឯកឧត្តម **ចាយ សាំងយ៉ុន** សហរដ្ឋលេខាធិការក្រសួងការពារជាតិ ជាសហប្រធាន

២_ឯកឧត្តម **ឯក សេរីវឌ្ឍន៍** សហរដ្ឋលេខាធិការក្រសួងការពារជាតិ ជាសហប្រធាន

៣_ឯកឧត្តម **ហូ សុខ** សហរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធាន

៤_ឯកឧត្តម **ឯម សំអាន** សហរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធាន

៥_ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន ជាសមាជិក

៦_ឯកឧត្តម **ឈា សុខ** រដ្ឋលេខាធិការក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ជាសមាជិក

៧_ឯកឧត្តម **ឌី ណារ៉ុងរិទ្ធ** រដ្ឋលេខាធិការក្រសួងសុខាភិបាល ជាសមាជិក

៨_ឯកឧត្តម **សូ ឃុន** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ជាសមាជិក

៩_ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋលេខាធិការក្រសួងពត៌មាន ជាសមាជិក

១០_ឯកឧត្តម **ម៉ុក សំឯល** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាសមាជិក

១១_ឯកឧត្តម **កែវ សាផល** អគ្គនាយកនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ជាសមាជិក

១២_ឯកឧត្តមបណ្ឌិត **ចែម វិឌ្ឍា** អគ្គលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាសមាជិក

**ប្រការ ២** : គណៈកម្មការនេះមានភារកិច្ចដូចតទៅ ÷

_រុករក និងជួយសង្គ្រោះយន្តហោះ និងនាវា ភ្ញៀវអ្នកដំណើរ និងសំភារៈនៅពេលដែលយន្តហោះ និងនាវាគ្រប់ប្រភេទ មានគ្រោះថ្នាក់ ។

_សំរបសំរួល និងទំនាក់ទំនងរវាងក្រសួង រដ្ឋលេខាធិការដ្ឋាន និងខេត្ត_ក្រុងពាក់ព័ន្ធដើម្បី ជំរុញការសហការជួយរុករកសង្គ្រោះយន្តហោះនិងនាវាពេលមានគ្រោះថ្នាក់ ។

_រៀបចំមជ្ឈមណ្ឌលប្រចាំការនិងផ្តល់ពត៌មាន ស្តីអំពីឧប្បត្តិហេតុនៃយន្តហោះនិងនាវា ។

–គណៈកម្មការនេះ ត្រូវប្រជុំបែងចែកភារកិច្ចជាក់ស្តែង និងរិះរកវិធានការថែមទៀតដើម្បីដំណើរការរុករកសង្គ្រោះយន្តហោះ និងនាវាអោយមានប្រសិទ្ធភាព ។

–រាល់សកម្មភាពរុករកសង្គ្រោះយន្តហោះ និងនាវាពេលមានឧប្បត្តិហេតុគណៈកម្មការត្រូវសរុបរបាយការណ៍ ព្រមទាំងការចំណាយផ្សេងៗ ក្នុងពេលចុះបំពេញបេសកកម្ម ដើម្បីដាក់ជូនរាជរដ្ឋាភិបាលជ្រាប និង សំរេច ។

–គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការពារជាតិ ។

**ប្រការ ៣** : សេចក្តីសំរេចលេខ៨៩ សសរ ចុះថ្ងៃទី ២៥–១២–១៩៩៥ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការសំរាប់រុករកជួយសង្គ្រោះយន្តហោះពេលមានឧប្បត្តិហេតុចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់ក្រសួង និងគ្រប់រដ្ឋលេខាធិការដ្ឋានដែលមានការពាក់ព័ន្ធ និងបណ្តាឯកឧត្តមដែលមាននាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខានិងត្រា | ហត្ថលេខានិងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

ភ្នំពេញ,ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៦

## សេចក្តីសំរេចលេខ ១៧ សសរ

## ស្តីពីគណៈកម្មការរៀបចំការអនុម័ត រាល់វិធានការការពារបេតិកភ័ណ្ឌស្ថាបត្យកម្ម និងនគររូបនីយកម្ម នៃទីក្រុងភ្នំពេញ

* * *